## របាយការណ៍សង្ខេប

# ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០២២

នៅថ្ងៃនេះ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា អាដហុក (ADHOC) ចេញផ្សាយនូវរបាយការណ៍មួយដែលមានចំណងជើងថា **ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០២២** ដែលនឹងបង្ហាញអំពីស្ថានភាពសិទ្ធិមនុស្ស សិទ្ធិដីធ្លី សិទ្ធិស្ត្រី និងកុមារ ដែលបានកើតមានឡើងចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២២។

ឆ្នាំ២០២២ សមាគមអាដហុក ធ្វើសកម្មភាព អង្កេត និងអន្តរាគមន៍ចំនួន ៩២១ករណី រួមមាន៖ ផ្នែកសិទ្ធិមនុស្សចំនួន៥៩៤ករណី និងសិទ្ធិដីធ្លីចំនួន៨៤ករណី និងផ្នែកស្ត្រី និងកុមារចំនួន២៨៨ករណី ដែលមានអ្នកទទួលសេវា (ជនរងគ្រោះ) សរុបចំនួន១០៧,៨៩៨នាក់ ផ្នែកសិទ្ធិមនុស្សចំនួន៤៦,៨១០នាក់(ស្ត្រី៣៣,៨៤៥នាក់) ផ្នែកសិទ្ធិដីធ្លីចំនួន៣៦,៧៦៦នាក់ (ស្ត្រី១៣,០១៥នាក់) និងផ្នែកស្ត្រី និងកុមារ ចំនួន ២៤,៣២២នាក់។

**១. ផ្នែកសិទ្ធិមនុស្ស:** ករណីរំលោភសិទ្ធិមនុស្ស កាន់តែមានសភាពធ្ងន់ធ្ងរឡើងដូចជា នៅក្នុងឆ្នាំ២០២២នេះ ផ្នែកសិទ្ធិមនុស្សនៃសមាគមអាដហុក ធ្វើសកម្មភាពសម្រេចបានលទ្ធផល ១០៤.៥% ធៀបនឹងផែនការប្រចាំឆ្នាំ។ តាមការអង្កេតបានបង្ហាញឲ្យឃើញថា ករណីរំលោភសិទ្ធិមនុស្ស មានចំនួនសរុប៥៤៩ករណី កើនឡើង៣៩២ករណីបើធៀបលទ្ធផលឆ្នាំ២០២១ មានត្រឹមតែ១៥៧ករណីប៉ុណ្ណោះ ក្នុងនោះករណីគំរាមកំហែងសកម្មភាពនយោបាយកើនឡើងរហូតដល់២១៨ករណី ការរឹតត្បឹតសេរីភាពជួបជុំចំនួន១១៨ករណី និងរឹតត្បឹតសេរីភាពបាតុកម្មចំនួន ៦៥ករណី។ ឆ្លងតាមការវិភាគបង្ហាញថា ជាង៥០% នៃករណីគម្រាមកំហែងសកម្មជនសិទ្ធិមនុស្ស សកម្មជននយោបាយ និងករណីរឹតត្បឹតសេរីភាពមូលដ្ឋាន នៅតែមិនត្រូវបានដោះស្រាយ។ ហើយភាគច្រើនបំផុតនៃជនរងគ្រោះករណីទាំងនោះ សំរេចមិនដាក់ពាក្យបណ្តឹង ពីព្រោះពួកគាត់មិនមានទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌។

- **លំហសេរីភាពនយោបាយ:** យោងតាមរបាយការណ៍ បរិយាកាសនយោបាយ នៅមុនពេលបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំ២០២២ សមាគមអាដហុកបានបង្ហាញថា៖ មានចំនួន ៨១ករណី បានកើតឡើងក្នុង ១៧ខេត្ត ៥០ស្រុក-ក្រុង ៦០ឃុំ-សង្កាត់ផ្សេងៗគ្នាមានដូចជា គំរាមកំហែងតាមរយៈប្រព័ន្ធតុលាការ បដិសេធលុបឈ្មោះបេក្ខជនចេញពីបញ្ជីឈ្មោះគណបក្ស គំរាម(តាមបណ្តាញសង្គម) បង្ករបួសស្នាម គំរាមឲ្យលាឈប់ពីបញ្ជីឈ្មោះបេក្ខភាពគណបក្ស បំផ្លាញស្លាកសញ្ញាគណបក្ស រារាំងការលើកស្លាកសញ្ញាគណបក្ស និងរឹតត្បឹតសេរីភាពជួបជុំសកម្មជនគណបក្ស។
- **ភាពមិនប្រក្រតីពីក្រោយការផ្តិតស្នាមមេដៃលើញត្តិគាំទ្រ:** ជាជ្រុងមួយ នៃយុត្តិធម៌សង្គម ក្នុងការអនុវត្តន៍ការងាររបស់អាជ្ញាធរមូលដ្ឋាន ដែលសមាគមអាហុក បានរកឃើញភាពមិនប្រក្រតិនៅពីក្រោយការគាំទ្រញាតិ៣៣ករណី មកពីបេក្ខភាពគណបក្សភ្លើងទៀនចំនួន១៦០នាក់ ដែលមានអាសនៈក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ស្ថិតនៅក្នុង៦៣ឃុំ-សង្កាត់ នៃខេត្តចំនួន១១គឺ ខេត្តកណ្តាល បាត់ដំបង តាកែវកំពត កំពង់ស្ពឺ កំពង់ចាម កោះកុង ស្ទឹងត្រែង ព្រៃវែង ព្រះសីហនុ និងខេត្តសៀមរាប។
- **ករណីទារុណកម្ម និងនិទណ្ឌភាព:** ជាជ្រុងមួយ នៃយុត្តិធម៌សង្គម ក្នុងការអនុវត្តន៍ការងាររបស់នគរបាលយុត្តិធម៌ ដែសមាគមអាដហុក ទទួលបានព័ត៌មានការធ្វើទារុណកម្មចំនួន១៤ករណីដែលមានជនរងគ្រោះដោយសារអំពើទារុណកម្មចំនួន២៧នាក់(ស្រីម្នាក់)។ ការធ្វើទារុណកម្មដោយហិង្សា ត្រូវបានធ្វើឡើងនូវក្នុងទីកន្លែងដែលជាអាគាររដ្ឋបាលសាធារណៈរបស់រដ្ឋដូចជា៖ ប៉ុស្តិ៍រដ្ឋបាលឃុំ-សង្កាត់អធិការដ្ឋានស្រុក-

ខណ្ឌ ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ពន្ធនាគារ(ត្រពាំងថ្លង) ហើយអ្នកដែលប្រើហឹង្សាធ្វើទារុណកម្មគឺមន្ត្រីយុត្តិធម៌ក្នុងតួនាទី មានដូចជា មន្ត្រីនគរបាលរដ្ឋបាលប៉ុស្តិ៍ មន្ត្រីនគរបាលអធិការដ្ឋាន មន្ត្រីនគរបាលស្នងការខេត្តមន្ត្រីកងរាជអាវុធហត្ថខេត្ត ព្រមទាំងមន្ត្រីអនុរក្សពន្ធនាគារ និងអ្នកទោសដូចគ្នាក្នុងពន្ធនាគារផងដែរ។ ការធ្វើទារុណកម្មក្នុងគោលបំណងបង្ខំឲ្យសារភាពបង្ខំឲ្យសងប្រាក់ បង្ក្រាបឲ្យបាក់ស្បាត។

- **បណ្ដឹងបរិហារៈ** មកត្រឹមបំណាច់ឆ្នាំ២០២២ សមាគមអាដហុក ទទួលបានព័ត៌មាន តំណាងសហគមន៍ចាប់ពីអំឡុងឆ្នាំ២០១៥ រហូតឆ្នាំ២០២១ តំណាងសហគមន៍ នៅក្នុងខេត្តចំនួន៥ បានរៀបចំឯកសារដាក់ពាក្យ បណ្ដឹងបរិហារចំនួន ១៩ករណី ទៅស្ថាប័នតុលាការ អំពីភាពមិនប្រក្រតិក្នុងការបំពេញតួនាទី របស់មន្ត្រីថ្នាក់ក្រោមជាតិ និងអ្នកមានទ្រព្យសម្បត្តិ(ឧកញ៉ា) កាប់រានឈូសឆាយដីព្រៃរបស់រដ្ឋយកជាកម្មសិទ្ធិឯកជន ការលក់ទិញ ដីព្រៃសម្បទានសេដ្ឋកិច្ច និងប្ដឹងពីការក្លែងលិខិតសាធារណៈចេញប្លង់កម្មសិទ្ធិដីធ្លីមិនប្រក្រតីសរុបជាងពីរម៉ឺនហិកតា។

**២. ផ្នែកសិទ្ធិដីធ្លីៈ** តាមការអង្កេតវិវាទដីធ្លី នៅតែបន្តកើតមានឡើងឥតឈប់ឈរ ទន្ទឹមនិងវិវាទរាំរ៉ៃមួយចំនួនធំមិនទាន់បានដោះស្រាយនៅឡើយ ខណៈវិវាទថ្មីៗទៀត បានកើតឡើងជាបន្តបន្ទាប់ នៅក្នុងឆ្នាំ២០២២ សមាគមអាដហុកបានរកឃើញ វិវាទដីធ្លីកើតឡើងចំនួន៨៤ករណី ដែល៥០% នៃវិវាទគឺជាករណីរំលោភដោយបុគ្គលមានអំណាច ដែលនាំឲ្យប៉ះពាល់ដល់ជនរងគ្រោះផ្ទាល់ ចំនួន៧,១៤១គ្រួសារ ស្មើ៣៦,៧៦៦នាក់ ដីវិវាទចំនួន៩,៨៣១.១១ហិកតា ជាង៩៧% នៃវិវាទត្រូវបានអូសបន្លាយការរកដំណោះស្រាយរហូតមកដល់បំណាច់ឆ្នាំ២០២២នេះ។

| **ផ្នែកសិទ្ធិដីធ្លី** | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ |
|---|---|---|---|
| ចំនួនករណីវិវាទ | ១៨២ | ១៦៩ | ៨៤ |
| ចំនួនជនរងគ្រោះ | ៧៧,៣៦១ | ៦១,៤៦៩ | ៣៦,៧៦៦ |
| ចំនួនដីប៉ះពាល់(ហិចតា) | ៥៧,០៨៦.៨៥ | ៥២,៦០១ | ៩,៨៣១.១១ |

**៣. ផ្នែកស្ត្រី និងកុមារៈ** នៅក្នុងឆ្នាំ២០២២ សមាគមអាដហុកបានរកឃើញ មានករណីរំលោភបំពាន់លើសិទ្ធិស្ត្រី និងកុមារ ចំនួន២៨៨ករណី កើនឡើង៦៤ករណី ធៀបនឹងរបកគំហើញឆ្នាំ២០២១ មានត្រឹមតែចំនួន២២៤ករណីប៉ុណ្ណោះ។ ករណីទាំងនោះរួមមានៈ ការជួញដូរផ្លូវភេទចំនួន៦១ករណី(បង្ខំរៀបការទៅប្រទេសចិន៥៧ករណី) ការជួញដូរកំលាំងពលកម្មចំនួន១៧ករណី (បំរើការក្នុងផ្ទះនៅប្រទេសម៉ាឡេស៊ីចំនួន១០ករណី) អំពើហិង្សាក្នុងគ្រួសារចំនួន៧៨ករណី (ហឹង្សារហូតដល់ស្លាប់ចំនួន២២ករណី) និងរំលោភសេពសន្ថវៈចំនួន១៣២ករណី(រំលោភសម្លាប់ចំនួន០៦ករណី)។

| **ផ្នែកសិទ្ធិស្ត្រី និងកុមារ** | **ឆ្នាំ២០២០** | **ឆ្នាំ២០២១** | **ឆ្នាំ២០២២** |
|---|---|---|---|
| ចំនួនករណី | ៣០៨ | ២២៤ | ២៨៨ |
| ចំនួនជនរងគ្រោះ | ៣៣១ | ២៥៦ | ៣១៥ |
| ចំនួនជនរងគ្រោះករណីហិង្សាក្នុងគ្រួសារស្លាប់ | ១៥ | ០៧ | ២២ |
| ចំនួនជនរងគ្រោះករណីរំលោភសម្លាប់ | ០៣ | ០៤ | ០៦ |


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖**

**លោក ស៊ឹង សែនករុណា អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក)**

**ទូរស័ព្ទ : ០៨៦ ៣២៤ ៦៦៦ / ០១៦ ៦៦ ២៦ ៤៥**